01157470

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception):
22 / 10 / 2015
ម៉ោង (Time/Heure): 11:00
មន្ត្រីមទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Sann Rada

002/19-09-2007-ECCC/TC
E1/339

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ អង្គារ៍ ទី ០១ ខែ កញ្ញា ឆ្នាំ ២០១៥

## សវនាការលើកស្តុតាង - ថ្ងៃ ៣២០

រៀបចំដោយ៖ **ឯម ហ៊ាយ** និង **Roger PHILLIPS**

| **កំណត់ហេតុអ្នកចូលរួម** |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម យ៉ា សុខន, ចៅក្រម Claudia FENZ , ចៅក្រម Jean-Marc LAVERGNE , ចៅក្រម យូ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី៖ លោក ឯម ហ៊ាយ, លោក Roger PHILLIPS |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក William Smith, លោក Vincent DE WILDE D'ESTMAEL, លោក សេង ប៊ុនឃាង |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក Victor KOPPE, លោក សុន អារុណ, លោក លីវ សុវណ្ណ |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |

| |
|---|
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Marie GUIRAUD, លោក ឡោ ជុនធី, លោក វ៉ែន ពៅ, លោក ពេជ អង្គ, លោក ហុង គឹមសួន, លោកស្រី ស៊ីន សុវ៉ន |
| សាក្សី/ដើមបណ្តឹង៖ នួន ណារុំ (2-TCCP-991), ថៅ ឡាង (2-TCCP-992) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ |
| ផ្សេងៗ៖ លោក ឡុង ង៉ែត, កញ្ញា ណី សុមេត្តា, កញ្ញា ស្រី ណាក់, លោក ឡាយ ណារ៉ា, លោក កើយ វិញគៀម, កញ្ញា Joëlle TRAMPERT |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៥ | ចាប់ផ្តើមម៉ោង៖ ០៩.០១ | បញ្ចប់ម៉ោង៖១៦.២៧ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.០៦ | បញ្ចប់ម៉ោង៖ ១០.៣១ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១១.៣១ | បញ្ចប់ម៉ោង៖ ១៣.២៩ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖១៤.៤១ | បញ្ចប់ម៉ោង៖ ១៥.00 |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៤ ម៉ោង និង ៥៤ នាទី |

| **កិច្ចដំណើរការនីតិវិធីផ្សេងទៀត** | | | |
|---|---|---|---|
| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ ក្រឡាបញ្ជី | ០៩.០១ | ០៩.០៤ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្តី នួន ជា | ០៩.០៤ | ០៩.០៦ |
| អង្គជំនុំជម្រះបានលើកសំណួរទាក់ទងនឹងការប្រើប្រាស់ឯកសារដែលមានជម្លោះ ដែលបានស្នើសុំដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី | អង្គជំនុំជម្រះ សហមេធាវីនាំមុខ | ០៩.០៦ ០៩.០៧ | ០៩.០៧ ០៩.១១ |

01157472



| | | | |
|---|---|---|---|
| ការតាំងសំណួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ (2-TCCP-991) | អង្គជំនុំជម្រះ<br>សហមេធាវីនាំមុខ<br>សហព្រះរាជអាជ្ញា<br>មេធាវីការពារក្តី នួន ជា<br>មេធាវីការពារក្តី ខៀវ សំផន | ០៩.១៣<br>៩.១៧<br>១០.៣១<br>១០.៥៤<br>១១.២២ | ០៩.១៧<br>១០.០៦<br>១០.៥៤<br>១១.២២<br>១១.៣០ |
| សេចក្តីសម្រេចរបស់អង្គជំនុំជម្រះលើបញ្ហាឯកសារគន្លឹះថ្ងៃ ២៨ សីហា ២០១៥ | អង្គជំនុំជម្រះ | ១៣.២៩ | ១៣.៤៤ |
| ការតាំងសំណួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឡាង (2-TCCP-992) | អង្គជំនុំជម្រះ<br>សហមេធាវីនាំមុខ<br>សហព្រះរាជអាជ្ញា<br>មេធាវីការពារក្តី នួន ជា<br>មេធាវីការពារក្តី ខៀវ សំផន | ១៣.៤៤<br>១៣.៤៩<br>១៥.០៧<br>១៥.៣០<br>១៥.៥២ | ១៣.៤៩<br>១៥.០៧<br>១៥.៣០<br>១៥.៥២<br>១៦.២៤ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ និងការប្រកាសពីវត្តមានរបស់ភាគីប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគី ទាំងអស់មានវត្តមាន។ ដោយឡែកជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោម សាលសវនាការ។

**សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឲ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**អង្គជំនុំជម្រះបានលើកសំណួរទាក់ទងនឹងការប្រើប្រាស់ឯកសារដែលជំទាស់ ដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

មេធាវីការពារក្តី ខៀវសំផន បានជំទាស់កាលពីលើកមុន ទៅនឹងការប្រើប្រាស់ឯកសារ E319/25.3.24 ដែលបានស្នើសុំដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

អង្គជំនុំជម្រះបានសួរទៅសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ថាតើខ្លួនរក្សាជំហរក្នុងការស្នើសុំប្រើប្រាស់ឯកសារ E319/25.3.24 នេះដែរឬទេ បន្ទាប់ពីដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-995 ត្រូវបានដកចេញពីបញ្ជីឈ្មោះដើមបណ្ដឹងរដ្ឋប្បវេណីដែលបានមកថ្លែងរៀបរាប់ទុក្ខសោកវេទនា និងព្យសនកម្ម នាពេលនេះ?

**<u>ការតាំងសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី នួន ណារុំ (2-TCCP-991)</u>**

អង្គជំនុំជម្រះបានតាំងសំណួរបឋមមួយចំនួនទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី (2-TCCP-991)។ បន្ទាប់មក សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី សហព្រះរាជអាជ្ញា មេធាវីការពារក្ដី នួន ជា និង មេធាវីការពារក្ដី ខៀវ សំផន បានធ្វើការតាំងសំណួរជាបន្តបន្ទាប់ទាក់ទងទៅនឹងទុក្ខសោកវេទនា និង ព្យសនកម្មដែលបានកើតឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។

**<u>អង្គជំនុំជម្រះសម្រេចទៅលើបញ្ហាបឋមដែលបានលើកឡើងអំឡុងពេលសវនាការអំពីឯកសារគន្លឹះ កាលពីថ្ងៃ ២៦ សីហា ២០១៥</u>**

នៅពេលសហព្រះរាជអាជ្ញាធ្វើការបង្ហាញឯកសារគន្លឹះកាលពីថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៥ សហមេធាវីការពារក្ដីអន្តរជាតិ លោក នួន ជា បានជំទាស់ទៅនឹងការបង្ហាញកំណត់នៃការស្ដាប់ចម្លើយសាក្សី ដែលទទួលបានពីការិយាល័យសហចៅក្រមស៊ើបអង្កេត។ ក្រោយមកទៀត ក្រុមមេធាវីការពារក្ដី នួន ជា និង ក្រុមមេធាវីការពារក្ដី ខៀវ សំផន បានដើរចាកចេញពីបន្ទប់សវនាការ។ នៅថ្ងៃទី ២៧ ខែសីហា ឆ្នាំ ២០១៥ អង្គជំនុំជម្រះ បានស្នើសុំឲ្យក្រុមមេធាវីការពារក្ដីនីមួយៗផ្ដល់នូវមូលដ្ឋានផ្លូវច្បាប់ ដើម្បីគាំទ្រលើការចាកចេញពីបន្ទប់សវនាការ កាលពីថ្ងៃមុន ។ គ្មានក្រុមមេធាវីការពារក្ដី អាចធ្វើបាននោះទេ។ លើសពីនេះ អង្គជំនុំជម្រះបានបញ្ជាក់ថា ភាគីនីមួយៗត្រូវបានអនុញ្ញាតឲ្យយោងទៅលើកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ក្នុងអំឡុងពេលសវនាការដេញដោលលើឯកសារគន្លឹះ ដែលវាជាតម្លៃ និងទម្ងន់នៃភស្តុតាងចាំបាច់ ហើយឯកសារទាំងនេះនឹងត្រូវបានពិចារណានៅចុងបញ្ចប់នៃសវនាការលើភស្តុតាងនេះ។ ហេតុដូច្នេះ ការជំទាស់របស់មេធាវីការពារក្ដី នួន ជា ត្រូវបានច្រានចោល។ អង្គជំនុំជម្រះបានបញ្ជាក់ថា សំណើរបស់ក្រុមមេធាវីការពារក្ដី ខៀវ សំផន ដែលលើកឡើងចំពោះ ឯសារ E363 នឹងត្រូវបានដោះស្រាយនៅពេលក្រោយ។ ក្រុមមេធាវីការពារក្ដី ខៀវ សំផន មិនបានធ្វើការជំទាស់ទៅនឹងសារណារបស់សហព្រះរាជអាជ្ញាដែលបានស្នើសុំដាក់ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ចំនួន ១៨ ចូលទៅក្នុងសំណុំរឿង ដែលបានយកចេញពីសំណុំរឿង០០៣ និង០០៤ នោះទេ ហើយអង្គជំនុំជម្រះ បានអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាធ្វើការបង្ហាញនូវឯកសារគន្លឹះទាំងនោះ។ ក្រុមមេធាវីការពារក្ដី ខៀវ សំផន ថែមទាំងបានជំទាស់ទៅ

នឹងការប្រើប្រាស់ឯកសារចំនួន ២ ដែលស្នើដោយសហព្រះរាជអាជ្ញា។ សហព្រះរាជអាជ្ញាបានយកឯកសារមួយចេញ ហើយអង្គជំនុំជម្រះ មិនបានអនុញ្ញាតឱ្យធ្វើការបង្ហាញឯកសារមួយទៀតនោះទេ ។

ពាក់ព័ន្ធទៅនឹងសេចក្តីថ្លែងការណ៍របស់លោក មេធាវី កូប៉េ កាលពីថ្ងៃ ២៧ ខែសីហា ឆ្នាំ២០១៥ ដែលបានធ្វើឡើង គឺវាហួសពីព្រំដែននៃឥរិយាបថនៅក្នុងបន្ទប់សវនាការ ហើយអង្គជំនុំជម្រះ នឹងធ្វើពិចារណាលើវិធានការសមស្របដែលត្រូវអនុវត្តចំពោះបញ្ហានេះ។

**<u>ការតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឡាង (2-TCCP-992)</u>**

អង្គជំនុំជម្រះបានតាំងសំណួរបឋមមួយចំនួនទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី (2-TCCP-992)។ បន្ទាប់មកសហមេធាវីនាំមុខ សហព្រះរាជអាជ្ញា មេធាវីការពារក្តី នួន ជា និង មេធាវីការពារក្តី ខៀវ សំផន បានធ្វើការតាំងសំណួរជាបន្តបន្ទាប់។

**<u>កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង</u>**

Reclassified

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/4909 | | 00541468-00541475; 01060570-01060575; 00906250-00906250 | Civil Party Application NUON Narom 09-VU-00540 | P | | | |
| E3/5965A | D22/339A | 00586026-00586027; N/A; N/A | Supplementary information of Civil Party Applicant | P | 00586027 | N/A | N/A |
| E3/5965 | D22/339 | 00484831-00484845; N/A; 00846972-00846973 | Civil Party Application of CHAO Lang 09-VU-01036 | P | 00484834 00484835 00484836 00484949 | N/A | 00846972 |
| E3/3104R | | V00172476-V00172476 | *Process des Khmer Rouges* | P | | | |

Other documents (No Change)

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E319/27.4.13 (*English version of E3/5965*) | D5/140.6 (*and D22/339*) | 01062372-01062389; 01098613-01098625; N/A | Civil Party application of CHAO Lang 13-VSS-00632 | SC | | 0109861501098616 01098624 | N/A |

**<u>ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖</u>**

- អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.០៤)
- បង្គាប់អោយអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់អោយនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញអោយបានមុនម៉ោង ៩.00 ព្រឹកនៅថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៥។ (១៦.២៧)

**<u>កាលវេលាសវនាការបន្ត</u>**

សវនាការនឹងបន្តទៅថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៥ ចាប់ផ្ដើមពីម៉ោង ០៩.00 ព្រឹក។

ភ្នំពេញ ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៥

ក្រឡាបញ្ជី ក្រឡាបញ្ជី

**ឯម ហ៊ី... ...ger PHILLIPS**